# សេចក្តីប្រកាសព័ត៌មាន

ក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម និង សហព័ន្ធស្រូវអង្ករកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា ដោយសារការផ្សព្វផ្សាយព័ត៌មានមួយចំនួនពីការឆ្លងរាតត្បាតនៃជំងឺឆ្លង កូវីដ១៩ (COVID-19) បានបន្តកើនឡើងក្នុងប្រទេសកម្ពុជា ជាហេតុធ្វើឱ្យមានក្តីបារម្ភដល់ប្រជាជនកម្ពុជាយើង ដែលអាចជះឥទ្ធិពលលើតម្លៃស្បៀងអាហារ ជាពិសេសគឺ ថ្លៃអង្ករ។

ឆ្លៀតក្នុងឱកាសនេះ ក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម និង សហព័ន្ធស្រូវអង្ករកម្ពុជា សូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋកម្ពុជាយើងសាជាថ្មីឱ្យបានជ្រាបថា បរិមាណសន្និធិអង្ករ និងស្រូវមិនទាន់កិន របស់សមាជិក សមាជិកាសហព័ន្ធស្រូវអង្ករកម្ពុជានៅទូទាំងប្រទេសលើទីតាំងចំនួនជាង៤០០រោងម៉ាស៊ីនកិនស្រូវ គឺមានបរិមាណគ្រប់គ្រាន់សម្រាប់ ផ្គត់ផ្គង់ជូនតាមតម្រូវការក្នុងស្រុក និងសម្រាប់នាំចេញ ស្របពេលដែលការប្រមូលផលស្រូវប្រាំង ២០១៩-២០២០ គិតត្រឹមថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ នេះគឺបាននឹងកំពុងប្រូតកាត់បានជាង៨០% ស្មើនឹងជាង ២.៣លានតោនស្រូវ ហើយតំបន់មួយចំនួនគឺចាប់ផ្តើមធ្វើការដាំដុះជាបន្តទៀត។

អាស្រ័យដូចនេះ ក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម និង សហព័ន្ធស្រូវអង្ករកម្ពុជា សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ កុំមានការភ័យព្រួយបារម្ភលើបញ្ហាខ្វះអង្ករ ដែលជាហេតុនាំឱ្យមានជនឆ្លៀតឱកាសនិយមមួយចំនួនឆ្លៀតដំឡើងថ្លៃអង្ករបាន។ សមាជិក សមាជិកាសហព័ន្ធស្រូវអង្ករកម្ពុជា រួមជាមួយក្រុមហ៊ុនហ្គ្រីនត្រេដ បានត្រៀមសន្និធិ និងលក្ខណៈគ្រប់គ្រាន់សម្រាប់លក់ជូនដល់ ទីផ្សារ ក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានានៅក្នុងប្រទេស។

សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម នៅបន្តដំណើរការបើកលក់អង្ករចាប់តាំងពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ រហូតអាចទប់ស្កាត់នៃការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ និងឈានទៅលុបបំបាត់ជំងឺនេះបានទាំងស្រុងពីកម្ពុជា តាមទីតាំងកំណត់មួយចំនួននៅរាជធានីភ្នំពេញដូចខាងក្រោម៖

- ស្នាក់ការក្រុមហ៊ុនហ្គ្រីនត្រេដ អាគារលេខ៦៥-៦៧-៦៩ ផ្លូវលេខ១៣៦ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ លេខទូរស័ព្ទ ០១២ ២៩៨ ៩២៥
- មណ្ឌលឃ្លាំងក្រុមហ៊ុនហ្គ្រីនត្រេដ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

**ក្នុងករណីដែលមានកង្វះខាតអង្ករ នៅតាមបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម រួមជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា នឹងដឹកអង្ករតាមរថយន្តធំ ទៅលក់ដល់ទីតាំងផ្ទាល់តែម្តង ដោយប្រើពេលវេលាមិនឱ្យលើសពីរយៈពេល២៤ម៉ោង។**

ក្រៅពីនេះបងប្អូនអាចស្វែងរកទិញផ្ទាល់ពីសមាជិក សមាជិកាសហព័ន្ធស្រូវអង្ករកម្ពុជាដូចជា៖

- ក្រុមហ៊ុនមេគង្គអូរីហ្សា លេខទូរស័ព្ទ ០៦៩ ២២៨ ២៥២
- ក្រុមហ៊ុមអេមរ៉ូរាយស៍ (ខេមបូឌា) លេខទូរស័ព្ទ ០១១ ៦២៦ ៣០៦
- ក្រុមហ៊ុនបៃតងកម្ពុជា លេខទូរស័ព្ទ ០៩៥ ៧១៧ ១៧១ / ០៦៩ ៣៤៣ ៤៣៤
- ក្រុមហ៊ុនខ្មែរហ្វ៊ុតគ្រុប លេខទូរស័ព្ទ ០៨៩ ២២២ ០២៨ / ០៨៩ ២២២ ០៣២
- រោងម៉ាស៊ីនវ៉ៃប៊ុនហេង លេខទូរស័ព្ទ ០៨៥ ៥៤៥ ៨៨៨
- រោងម៉ាស៊ីនអៀងហ៊ាង លេខទូរស័ព្ទ ០៨៥ ២៤២ ៦៤៥ / ០៨៩ ៤៥៩ ៥៥៨
- រោងម៉ាស៊ីនហាក់ សែ លេខទូរស័ព្ទ ០១២ ៥០០ ៤០០ / ០១០ ៦៥០ ៦៥១

**សេវាដឹកជញ្ជូនដល់ទីតាំង**

- ក្រុមហ៊ុនក្រុមហ៊ុន ហាយឡេវែលឡូជីស្ទិក (High Level Logistics) ទូរស័ព្ទ 099 918988
- ក្រុមហ៊ុន Ocean network logistics & transport ទូរស័ព្ទ 099 918988
- ក្រុមហ៊ុនតែតជ្រេល អញ្ញាត្រេត ឯ.ក លេខទូរស័ព្ទ ០១២ ៨៦៣ ០១២ / ០១៥ ៨៦៣ [illegible]